# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៧៦ / ១៩.៣.២០១០
សាលដីកា
លេខ: ១៣ ក្រ.III.ស / ០៣.១០.២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងទាស់ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៧៦ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ រវាង ៖

១. ជនជាប់ចោទឈ្មោះ [redacted] លីណា ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើនំបញ្ចុក ទីលំនៅកំណើត និងទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

ចាប់ខ្លួនថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៨, ឃុំខ្លួនថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ ។

២. ជនជាប់ចោទឈ្មោះ [redacted] មឿន ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅកំណើត និងទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

ចាប់ខ្លួនថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៨, ឃុំខ្លួនថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ ។

មានលោក [redacted] ម៉ាច ជាមេធាវីការពារជនជាប់ចោទទាំងពីរនាក់។

ជាប់ចោទពីបទៈ ប៉ុនប៉ងមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅចំណុចអូរគួស ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ បទល្មើស ព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅ ភូមិប្រជាត់ ឃុំកាព ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

## ៦ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ នៅចំណុចអូរគួស ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ឈ្មោះ អ៊ាង និងឈ្មោះ អឿន បានបបួលឈ្មោះ [redacted] វិជ្ជា, មឿន, [redacted] លីណា និងឈ្មោះ [redacted] បូផាន់ ទៅកាប់ឈ្មោះ ហ៊ឹម ដោយថា ឈ្មោះនេះមើលងាយខ្លួន។ បន្ទាប់ពីយល់ព្រមឯកភាពគ្នាហើយ ឈ្មោះ អ៊ាង, ប៉ុន វិជ្ជា, មឿន, [redacted] លីណា និងឈ្មោះ [redacted] បូផាន់ កាន់កាំបិតផ្គាក់ម្នាក់មួយ ឈ្មោះ អឿន កាន់កាំភ្លៀវ១ និងឈ្មោះ [redacted] មឿន កាន់ព្រនង់មួយទៅព្រួតគ្នាកាប់ និងវាយទៅលើឈ្មោះ [redacted] ហ៊ឹម, [redacted] រស់ និងឈ្មោះ [redacted] ទ្បៃ បណ្តាលឲ្យរបួសជាទម្ងន់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧៥ «ក» ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ របស់ សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១. ផ្តន្ទាទោសឈ្មោះ [redacted] លីណា ភេទប្រុស អាយុ២២ឆ្នាំ និងឈ្មោះ [redacted] មឿន ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៨ ពីបទ ប៉ុនប៉ងប្រព្រឹត្តអំពើឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចអូរគួស ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

២. ឲ្យឈ្មោះ [redacted] បូផាន់ ភេទប្រុស អាយុ១៣ឆ្នាំ រួចផុតពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌ

៣. ទុកសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] ទ្បៃ, ឈ្មោះ [redacted] ហ៊ឹម និងឈ្មោះ [redacted] រស់ ប្តឹងទាមទារ សំណងទៅតុលាការរដ្ឋប្បវេណី។

៤. វត្ថុតាងមានៈ កាំបិតផ្គាក់០២ ដំបងដើមផ្កាវ២ កាំភ្លៀវ១ អាវយឺតពណ៌ខៀវ១ មួកខូវប៊យ១ ត្រូវរឹបអូសបំផ្លាញចោល។

៥. សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីណា និងឈ្មោះ [redacted] មឿន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បូផាន់ បើកផ្លូវប្តឹងឧទ្ធរណ៍ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។៤

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] មឿន និងឈ្មោះ [redacted] លីណា ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៥ «ក» ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តក្រចេះ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៧៤«ក្រ.III.ស» ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទ ឈ្មោះ [redacted] មឿន និងឈ្មោះ [redacted] លីណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៥ «ក» ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការពេញទាំងមូល។

៣. បង្គាប់ឲ្យបន្តនូវការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

បានឃើញពាក្យបណ្តឹងទាស់ លេខ ៤១ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] លីណា និងឈ្មោះ [redacted] មឿន ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ ៧៤ ក្រ.III.ស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## <u>នាពេលសវនាការ</u>

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយនៅសាលាដំបូងខេត្តក្រចេះ។

ជនជាប់ចោទឈ្មោះ [redacted] លីណា និងឈ្មោះ [redacted] មឿន ឆ្លើយថា ពួកខ្លួនគ្មានទំនាស់ជាមួយភាគីជនរងគ្រោះទេ តែពេលនោះ ពួកខ្លួនត្រូវបានឈ្មោះ អ៊ាង ហៅឲ្យទៅជាមួយវា ដើម្បីព្រមានជនរងគ្រោះ ដោយឈ្មោះ [redacted] ថា ភាគីជនរងគ្រោះមើលងាយពួកគេ។ ពួកខ្លួនទៅតាមឈ្មោះ [redacted] តែមិនមានចេតនាវាយសម្លាប់ជនរងគ្រោះទេ គឺទៅដើម្បីវាយតប់ដោយជម្លោះប៉ុណ្ណោះ គឺជម្លោះរវាងឈ្មោះ អ៊ាង និងបក្សពួកម្ខាងទៀត ជាជនរងគ្រោះ, ពេលនោះក៏មានការវាយគ្នាទៅវិញទៅមក។

## <u>សេចក្តីសន្និដ្ឋានរបស់តំណាងមហារយអ្យការ</u>

តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា ជនរងគ្រោះត្រូវបានជនជាប់ចោទកាប់នឹងកាំបិត

ផ្តាក់, តាមអង្គហេតុជនរងគ្រោះត្រូវបានជនជាប់ចោទព្រួតគ្នាកាប់ វាយ និងមានការពួនគេច ឃើញថា មិនមានលក្ខណៈស៊ីសង្វាក់គ្នា ព្រោះការប្រព្រឹត្តផ្តើមចេញពីជម្លោះទៅវិញទៅមក សូមសភាព្រហ្មទណ្ឌ ពិចារណាធ្វើការកែប្រែបទចោទ និងផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទ។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវី</u>

ឃើញថានៅក្នុងរឿងនេះ មានអង្គហេតុ២ មុននឹងកើតរឿង មានទំនាស់ទី១ គឺអង្គហេតុឈ្មោះ អ៊ាង បានមានទំនាស់ជាមួយក្រុមជនរងគ្រោះឈ្មោះ [redacted] ធីម, [redacted] រស់ ប្រមាថគ្នារកបាញ់ ឈ្មោះ អ៊ាង នេះក៏បានត្រឡប់មកដល់រោង ក៏បបួលកូនក្តីខ្លួន និងមនុស្ស៤, ៥នាក់ ទៀតទៅ ហើយនៅខាងនោះ ក៏មានគ្នា ៤, ៥នាក់ ដែរ ឈ្មោះ [redacted] ធីម, ឈ្មោះ [redacted] រស់, ឈ្មោះ [redacted] ទ្បៃ, ឈ្មោះ [redacted] ស៊ីណាត ជាក្រុម ដូចតំណាងមហាអយ្យការបានលើកឡើងអញ្ចឹង ក៏កើតមានទំនាស់ដូចការវាយ និងកាប់គ្នា ដោយឡែកកូនក្តីខ្លួន២នាក់នេះ គាត់បានឆ្លើយតាំងពីនៅដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ ពេលនេះ គាត់ថា គាត់ពិតជាបានទៅមែន ក្រោយពីគេបបួល ប៉ុន្តែនៅពេលជិតទៅដល់កន្លែងកើត ហេតុដែលគេកាប់គ្នានោះគឺ គាត់ចូលនោម អញ្ចឹងឈ្មោះ អ៊ាង និងឈ្មោះ ជា ដើរទៅមុន ហើយក៏មាន ការកាប់គ្នាឡើង អញ្ចឹងកូនក្តីខ្លួនគាត់ថា គាត់មិនបានកាប់ទេ តែគាត់បានទទួលស្គាល់ថាពិតជា បានទៅ ហើយការទៅរបស់គាត់គឺអត់មានកាន់អ្វីទេ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដែលទៅជាមួយគ្នា គឺគាត់បានបញ្ជាក់ថា ឈ្មោះ មឿន នោះគឺគាត់កាន់ព្រនង់ឈើ ហើយ ឈ្មោះ [redacted] លីណា ពុំដឹងកាន់អ្វីទេ។ ហើយនៅពេលដែលគាត់ដើរ គឺគាត់បានចូលបត់ជើងតូច ហើយស្រាប់តែឈ្មោះ អ៊ាង ស្រែកឡូឡាក៏មានការកាប់គ្នាទៅ។ ហើយតាមចម្លើយរបស់ជនរងគ្រោះ ឈ្មោះ [redacted] ស៊ីណា ជាដើមបណ្តឹង ក៏បានបញ្ជាក់ថា អ្នកដែលកាប់គឺមានឈ្មោះ [redacted] ឈ្មោះ អឿន ឈ្មោះ ជា ជាអ្នកកាប់ អញ្ចឹងចម្លើយនេះមានភាពស៊ីសង្វាក់គ្នា ហើយគាត់ក៏បានអះអាងថា គាត់អត់ បានកាប់ទៅលើជនរងគ្រោះនោះទេ គ្រាន់តែថាបានទៅតាមការបបួល ក្នុងនាមអ្នកស្គាល់គ្នាក៏ទៅ ជាមួយគ្នាដែរទៅ។ ដូចនេះ អ្នកដែលដៃដល់ អ្នកដែលប្រព្រឹត្តក្នុងការធ្វើប៉ុនប៉ង ឃាតកម្មនេះគឺឈ្មោះ អឿន ឈ្មោះ អ៊ាង នោះទេ អញ្ចឹងកូនក្តីខ្លួនគាត់ពុំមានចេតនាអ្វីថាទៅសំលាប់គេទេ ព្រោះគាត់គ្មាន កាំបិតអ្វីទេ មានតែឈើមួយនៅនឹងដៃ ក្នុងការដើរព្រៃ គាត់អាចកាន់ដើម្បីការពារសត្វជាតុ, ឃើញថា កន្លងមកកូនក្តីខ្លួនក៏មិនដែលប្រព្រឹត្តអ្វីខុសឆ្គងនៅក្នុងសង្គមដែរ ហើយនេះគឺជាលិខិតមួយដែលប្រជា ពលរដ្ឋក្នុងភូមិ ដែលមានមេភូមិទទួលស្គាល់ថា គាត់ជាប្រជាពលរដ្ឋល្អមួយនៅក្នុងសង្គម ដែលមិន ដែលបង្កទំនាស់អ្វីនៅក្នុងភូមិឃុំទេ ដូចនេះការផ្តន្ទាទោសគាត់១៥ឆ្នាំនេះ ឃើញថាមានលក្ខណៈ ធ្ងន់ធ្ងរណាស់ធ្វើឲ្យប៉ះពាល់អនាគតគាត់ សូមឲ្យក្រុមប្រឹក្សាមេត្តាពិនិត្យ និងការប្រើបទចោទធ្ងន់ធ្ងរ យ៉ាងម៉េច សុំឲ្យផ្តល់ស្ថានសម្រាលទោសឲ្យបានច្រើនតាមមាត្រា ៩៣, ៩៤ ដើម្បីឲ្យគាត់មានឱកាស

ក្នុងការកែប្រែខ្លួនផង។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

**សភាព្រហ្មទណ្ឌ**

**យល់ឃើញថាៈ**

១. បណ្តឹងទាស់លេខ ៤១ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ល័ណា និង ឈ្មោះ [redacted] មឿន ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទថា ពួកខ្លួនគ្មានទំនាស់ជាមួយភាគីជនរងគ្រោះទេ តែពេលនោះ ពួកខ្លួនត្រូវបានឈ្មោះ អ៊ាង ហៅឲ្យទៅជាមួយវា ដើម្បីព្រមានជនរងគ្រោះ ដោយឈ្មោះ [redacted] ថា ភាគីជនរងគ្រោះមើលងាយពួកគេ។ ពួកខ្លួនទៅតាមឈ្មោះ អ៊ាង តែមិនមានចេតនាវាយសម្លាប់ជនរងគ្រោះទេ គឺទៅដើម្បីវាយតប់ដោយជម្លោះប៉ុណ្ណោះ គឺជម្លោះរវាងឈ្មោះ អ៊ាង និងបក្សពួកម្ខាងទៀតជាជនរងគ្រោះ, ពេលនោះក៏មានការវាយគ្នាទៅវិញទៅមក។

៣. កាលពីថ្ងៃកើតហេតុ គឺហេតុការណ៍កើតឡើងដោយជម្លោះទាស់ទែងគ្នា រវាងមនុស្សពីរក្រុមផ្សេងគ្នា គឺក្រុមជនជាប់ចោទ និងជនរងគ្រោះ ដែលមានទំនាស់នឹងគ្នា ក៏កើតទៅជាវាយប្រហារគ្នាទៅវិញទៅមក ពុំមែនកើតឡើងដោយភាគីជនជាប់ចោទរៀបចំគម្រោងពួនស្ទាក់វាយប្រហារកាប់សម្លាប់ជនរងគ្រោះទេ, ប៉ុន្តែ ហេតុការណ៍បានឡើងកម្រិតខ្ពស់ ដោយភាគីជនរងគ្រោះមានសភាពទន់ជាង ក៏ត្រូវទទួលរងគ្រោះធ្ងន់តាមទំហំតទល់ដោយកំហឹង។

៤. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ ប៉ុនប៉ងឃាតកម្មដោយចេតនា ប្រព្រឹត្តនៅចំណុច អូរគួស ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

ដូច្នេះ គួរកែប្រែបទចោទឲ្យបានត្រឹមត្រូវ និងសម្រេចឡើងវិញ តាមបទចោទដែលបានកែប្រែ។

៥. ចំណុចទី២ នៃសាលដីកាព្រហ្មទណ្ឌលេខ ៧៤ ក្រ.III.ស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ សម្រេចមានការខ្វះខាត គួរកែប្រែឡើងវិញ ដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១. ទទួលបណ្ដឹងទាស់លេខ ៤១ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted]លីណា និងឈ្មោះ [redacted]មឿន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។

២. កែប្រែចំណុចទី២ នៃសាលដីកាព្រហ្មទណ្ឌលេខ ៧៤ ក្រ.III.ស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ជាៈ

" បដិសេធចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៧៥ «ក» ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តក្រចេះ ចោល " ហើយសម្រេចឡើងវិញថាៈ

ក. កែប្រែបទចោទលើជនជាប់ចោទ ពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ទៅជាបទ ប៉ុនប៉ងឃាតកម្មដោយចេតនា ប្រព្រឹត្តនៅចំណុចអូរគូស ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា៤ នៃច្បាប់ ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ខ. ផ្ដន្ទាទោសឈ្មោះ [redacted] លីណា ភេទប្រុស អាយុ២២ឆ្នាំ និងឈ្មោះ [redacted] មឿន ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ១០(ដប់)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៨ ពីបទ ប៉ុនប៉ងឃាតកម្មដោយចេតនា ប្រព្រឹត្តនៅចំណុចអូរគូស ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ, បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted] |

---

| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី...11... ខែ វិច្ឆិកា ឆ្នាំ ២០១៤ |
| | ក្រឡាបញ្ជី |